អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា
Kampuchea Action to Promote Education (KAPE)

# សេចក្តីណែនាំ និងឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ

## ឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ

អ្នកដេញថ្លៃទាំងអស់ ត្រូវភ្ជាប់ជាមួយនូវឯកសារភស្តុតាង បង្ហាញពីលក្ខណៈសម្បត្តិរបស់ខ្លួនមានដូចខាងក្រោម៖

- វិញ្ញាបនបត្រចុះឈ្មោះក្រុមហ៊ុន ឬអាជីវកម្ម ក្នុងបញ្ជីក្រសួងពាណិជ្ជកម្ម (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់
- ប័ណ្ណប៉ាតង់ប្រចាំឆ្នាំ២០២៤ (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់
- ឯកសារភស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាពបច្ចេកទេស និងបទពិសោធន៍ក្នុងការផ្គត់ផ្គង់របស់ខ្លួន ០១ ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ ឬលិខិតឆ្លងដែន (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់

ក្រុមហ៊ុន ឬអាជីវករ និងអ្នកទទួលការផ្គត់ផ្គង់សម្ភារព័ត៌មានវិទ្យា ទាំងអស់ដែលមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ក្នុងករណីពិនិត្យឃើញថា៖ ក្រុមហ៊ុន ឬអាជីវករ និងអ្នកទទួលការផ្គត់ផ្គង់ដែលបានចូលរួមធ្វើការដេញថ្លៃជាក្រុមហ៊ុនមានសម្ព័ន្ធភាពតែមួយ ឬប្រភពតែមួយ នឹងត្រូវបដិសេធដោយស្វ័យប្រវត្តិ។

<u>បញ្ជាក់</u>៖

1. ការទទួលពាក្យ មានឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃនិងពាក្យសុំចូលរួមដេញថ្លៃ ឯកសារសម្រង់តម្លៃ ចាប់ពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦ រហូតដល់ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៦ វេលាម៉ោង ៥:០០នាទី ល្ងាចជាកំហិត។
2. ការបើកកញ្ចប់ដេញថ្លៃធ្វើដោយផ្ទាល់នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៦ វេលាម៉ោង ៩:៣០នាទី ព្រឹកនៅបន្ទប់ប្រជុំរបស់អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) ក្នុងបរិវេណ (សាលាគរុកោសល្យ និង វិក្រឹតការ ខេត្តកំពង់ចាម) ភូមិទី៦ សង្កាត់ វាលវង់ ក្រុង កំពង់ចាម ខេត្ត កំពង់ចាម។
3. រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ ត្រូវប្រេកក្នុងស្រោមបិទជិត ដោយមានចុះហត្ថលេខា និងបោះត្រារបស់ក្រុមហ៊ុន ឬម្ចាស់អាជីវកម្ម នៅលើស្រោមសំបុត្រ រួចបញ្ជូនមកការិយាល័យអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) ដែលមានអាសយដ្ឋានខាងលើ។ រាល់ឯកសារសម្រង់តម្លៃដេញថ្លៃទាំងអស់ ត្រូវគិតជាប្រាក់រៀលបញ្ចូលពន្ធអាករលើតម្លៃបន្ថែម ១០% ទៅតាមមុខសម្ភារព័ត៌មានវិទ្យានីមួយៗ ហើយហាមដាច់ខាតមិនអនុញ្ញាតឱ្យដាក់ផ្ញើមកតាមរយៈសារអេឡិចត្រូនិច (អ៊ីមែល តេឡេក្រាម WhatsApp.....) ឡើយ។ រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ ដែលមិនបានដាក់ជូនមកការិយាល័យរបស់អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ទាន់ពេលវេលាទេ ត្រូវចាត់ទុកជាអាសាបង់ និងទុកជានិរាករណ៍។
4. អ្នកចូលរួមដេញថ្លៃទាំងអស់ត្រូវអញ្ជើញមកចូលរួមប្រជុំស្តាប់ការបើកកញ្ចប់ដេញថ្លៃឱ្យទាន់ពេលវេលា។ ប្រសិនបើអ្នកដេញថ្លៃណាដែលមានសិទ្ធិចូលរួមហើយតែមិនបានចូលរួមប្រជុំបើកសម្រង់តម្លៃទាន់ពេលវេលាឬក៏អវត្តមានក្នុង (រយៈពេល ១៥នាទី) ឯកសារដាក់ដេញថ្លៃនោះមិនអនុញ្ញាតដាក់បញ្ចូលក្នុងការបើកឡើយ។
5. ចំពោះអ្នកចូលរួមប្រជុំការបើកបញ្ចប់ឯកសារដេញថ្លៃទាំងអស់ ដែលជាអ្នកមកតំណាងក្រុមហ៊ុន ឬអាជីវករ និងអ្នកផ្គត់ផ្គង់ ត្រូវមានលិខិតផ្ទេរសិទ្ធិ ដែលមានចុះហត្ថលេខាត្រឹមត្រូវពីប្រធានក្រុមហ៊ុន ឬម្ចាស់អាជីវកម្ម។
6. យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរនៃការបើកកញ្ចប់ឯកសារដេញថ្លៃ ប្រសិនបើមានការចាំបាច់ ហើយយើងខ្ញុំនិងជូនដំណឹងទៅក្រុមហ៊ុន ឬអាជីវករ និងអ្នកទទួលការផ្គត់ផ្គង់ដែលបានផ្ញើឯកសារដេញថ្លៃមកជាមុន)
7. រាល់ឯកសារដេញថ្លៃដែលបានដាក់មកហើយ គណៈកម្មការយើងខ្ញុំមិនប្រគល់ជូនត្រឡប់ទៅវិញទេ។